តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ០៦

ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩

សាលដីកា

លេខ: ១២ (I)

ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សាលដីកា

## តាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធាន

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រម

៥.លោកស្រី [redacted] ចៅក្រមរបាយការណ៍

### ក្រឡាបញ្ជីសវនាការ

លោក [redacted]

### តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

### ដើម្បីជំនុំជម្រះ

នៅលើបណ្តឹងសាទុក្ខលេខ ៣២ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ របស់លោកមេធាវី [redacted] ណាក់ ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៧៣ ក្រIII "ស.អ" ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ដែលមាន៖

**ជនជាប់ចោទ៖**

-ឈ្មោះ [redacted] គង់ ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតនិងទីលំនៅបច្ចុប្បន្ន [redacted] ខេត្តស្វាយរៀង ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ



Scanned with CamScanner

[redacted](វ) មានប្រពន្ធឈ្មោះ [redacted] កូនគ្មាន ជាទីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ (អ្នកប្តឹងសាទុក្ខ)

មេធាវីការពារសិទ្ធិ៖ លោក [redacted] ណាក់ ។

<u>ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖</u> បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន បណ្តាលឱ្យរបួស និងស្លាប់អ្នកដទៃ ដោយអចេតនា និងបទ រត់គេច ប្រព្រឹត្តនៅចំណុច ភូមិគគ្រួស ឃុំព្រៃធំ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៨៣ មាត្រា៨៥ នៃច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក និងមាត្រា៥៤៣ នៃក្រមព្រហ្មទណ្ឌ ។

<u>**ដើមបណ្តឹងរដ្ឋប្បវេណី៖**</u>

១-ឈ្មោះ [redacted] វិជ្ជា ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ មុខរបរឃោជា ទីលំនៅកំណើត និងទីលំនៅបច្ចុប្បន្ន [redacted] ខេត្តស្វាយរៀង។

២-ឈ្មោះ [redacted] សាម៉ុន ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករ ទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តស្វាយរៀង។

**អំពីអង្គហេតុ**

កាលពីថ្ងៃអង្គារ ទី១៥រោច ខែបុស្ស ឆ្នាំរកា ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨ វេលាម៉ោង ១៨ និង៣០នាទី លើផ្លូវលំក្រាលខ្សាច់ភ្ជុំត្រង់ចំណុចភូមិគគ្រួស ឃុំព្រៃធំ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង មានករណីគ្រោះថ្នាក់ចរាចរណ៍មួយកើតឡើង បង្ករដោយគោយន្តកែច្នៃមួយគ្រឿងពណ៌ខៀវ គ្មានស្លាកលេខប្រភេទកែច្នៃដឹកដី បើកបរដោយឈ្មោះ [redacted] គង់ ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅភូមិគគ្រួស ឃុំព្រៃធំ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ដែលកំពុងបើកគោយន្តក្នុងទិសដៅពីត្បូងទៅជើងក្នុងស្ថានភាពគ្មានភ្លើងបំភ្លឺផ្លូវ ក៏មានម៉ូតូមួយគ្រឿងម៉ាក SUXUKI NEX ពណ៌សលាយក្រហម ស្លាកលេខ ស្វាយរៀង 1k-1256 បើកបរដោយឈ្មោះ [redacted] សុវណ្ណរិទ្ធី ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស ដោយមានអ្នករួមដំណើរម្នាក់ឈ្មោះ [redacted] សាលី ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស បើកបរក្នុងទិសដៅបញ្ច្រាស់គ្នាពីជើងទៅត្បូង តែដោយគោលយន្តកែច្នៃពុំមានភ្លើងបំភ្លឺផ្លូវក៏បានទៅបុកម៉ូតូចំពីមុខ ពេញទំហឹងបណ្តាលឱ្យម៉ូតូដួលខ្ទាត់ចូលចន្លោះដើមប្រេងខ្យល់ និងបង្គោលដែកធ្វើឱ្យស្លាប់អ្នកបើកបរម៉ូតូ ឈ្មោះ [redacted] សុវណ្ណរិទ្ធិ នៅនឹងកន្លែងកើតហេតុនិងរងរបួសធ្ងន់អ្នករួមដំណើរឈ្មោះ [redacted] សាលី ត្រូវបានក្រុមគ្រួសារបញ្ជូនទៅមន្ទីរពេទ្យខេត្តស្វាយរៀង។ ចំណែកអ្នកបើរបរគោយន្តកែច្នៃឈ្មោះ [redacted] គង់ បានបើកគោយន្តរត់គេចខ្លួនពីកន្លែងកើតហេតុ យកទៅលាក់ទុកនៅផ្ទះរបស់ខ្លួនតែម្តង។ ក្រោយពីកើតហេតុសមត្ថកិច្ចក៏បានចុះធ្វើការស្រាវជ្រាវ និងកសាងសំណុំរឿងបញ្ជូនមកអយ្យការចាត់ការតាមនីតិវិធី។

Scanned with CamScanner

-បានឃើញ ដីកាសម្រេចមិនឃុំខ្លួនជាបណ្ដោះអាសន្ន លេខ ៥៥០ សរ.មឃខ/១៨ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តស្វាយរៀង ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

-មិនឃុំខ្លួនឈ្មោះ [redacted] គង់ ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ មានទីកន្លែងកំណើតនិងបច្ចុប្បន្ន [redacted] ខេត្តស្វាយរៀង។ ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) មានប្រពន្ធឈ្មោះ [redacted] កូនគ្មាន ជានីតិជន ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន។

-ត្រូវចោទពីបទៈ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្ដាលឲ្យរបួស និងស្លាប់អ្នកដទៃដោយអចេតនា និងបទ រត់គេច ប្រព្រឹត្តនៅចំណុច ភូមិគគ្រួស ឃុំព្រៃធំ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា៨៣ មាត្រា៨៥ នៃច្បាប់ស្ដីពី ចរាចរណ៍ផ្លូវគោក និងមាត្រា៥៤៣ នៃក្រមព្រហ្មទណ្ឌ ដោយអនុញ្ញាតឲ្យមានសេរីភាពជាធម្មតា តែត្រូវឲ្យជននេះចូលទៅបង្ហាញខ្លួនចំពោះតុលាការ គ្រប់ពេលដែលមានដីកាកោះហៅរបស់តុលាការ។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ១២ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ របស់លោក [redacted] ព្រះរាជអាជ្ញា និងជាតំណាង អយ្យការ និងដីកាសម្រេចមិនឃុំខ្លួន បណ្ដោះអាសន្នលេខ ៥៥០សរ .មឃខ/១៨ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៧៣ ក្រIII "ស.អ" ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១-ទទួលបណ្ដឹងឧទ្ធរណ៍លេខ ១២ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងខេត្តស្វាយរៀង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-បដិសេធចោលដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្នលេខ ៥៥០ សរ.មឃខ/១៨ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តស្វាយរៀង ជាអសារបង់ ។

៣-បង្គាប់ឲ្យចាប់ខ្លួន-ឃុំខ្លួនជាត្រូវចោទឈ្មោះ [redacted] គង់ ភេទប្រុស អាយុ៣០ឆ្នាំ (អត្តសញ្ញាណដូចខាងលើ) ត្រូវចោទពីបទ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្ដាលឲ្យរបួស និងស្លាប់ដល់អ្នកដទៃដោយអចេតនា និងបទ រត់គេច ប្រព្រឹត្តនៅចំណុចភូមិគគ្រួស ឃុំព្រៃធំ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា៨៣ មាត្រា៨៥ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក និងមាត្រា ៥៤៣ នៃក្រមព្រហ្មទណ្ឌ។

៤-បង្គាប់ឲ្យកំលាំងសមត្ថកិច្ច មន្ត្រីនគរបាលយុត្តិធម៌ពាក់ព័ន្ធស្វែងរកចាប់ខ្លួនជនត្រូវចោទ ឈ្មោះ [redacted] គង់ ភេទប្រុស អាយុ៣០ឆ្នាំ (អត្តសញ្ញាណដូចខាងលើ) នាំយកមកឃុំខ្លួនទៅពន្ធនាគារខេត្តស្វាយរៀង ។

Scanned with CamScanner

៥-សាលដីកានេះប្រកាសជាសាធារណៈនាថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានសុំថា៖

សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍បានសម្រេច បដិសេធចោលសាលដីកាសម្រេចមិនឃុំខ្លួនជាបណ្តោះអាសន្នលេខ ៥៥០ ស.រ ម.ឃ.ខ/១៨ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តស្វាយរៀងជាអាសាបង់គឺមានលក្ខណៈត្រឹមត្រូវហើយ។ ដោយផ្អែកតាមសំអាងហេតុបានបញ្ជាក់ថា អង្គហេតុនៃរឿងនេះ គឺផ្តើមចេញពីជនត្រូវចោទ ដោយបង្ករឡើងដោយជនត្រូវចោទ បានធ្វើឲ្យបង្កររបួសបណ្តាលឲ្យស្លាប់ដល់អ្នកដទៃ ហើយបានរត់គេចខ្លួននៅកន្លែងកើតហេតុ ដោយបើកបរគោយន្តរបស់ខ្លួនគ្មានសញ្ញាបំភ្លឺផ្លូវ បើកបរនៅពេលយប់ដែលធ្វើឲ្យជនរងគ្រោះបើកម៉ូតូបុករហូតដល់ស្លាប់ និងរបួសដោយពុំទាន់បានទទួលសំណងគ្រប់នៅឡើយ។

ដូចនេះសំអាងហេតុដែលសាលាឧទ្ធរណ៍ បានបង្ហាញនេះគឺមានភស្តុតាងត្រឹមត្រូវ ដូចនៅក្នុងចំណុច ៣,៤ នៃសំអាងហេតុនោះស្រាប់។

## <u>តំណាងមហាអយ្យការស្នើក្រុមប្រឹក្សាជំនុំជម្រះសម្រេច</u>

១-ទទួលបណ្តឹងសាទុក្ខលេខ ៣២ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ របស់លោក [redacted]ណាក់ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-តម្កល់ សាលដីកាព្រហ្មទណ្ឌ ៧៣ "ក្រIIIស.អ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ ទុកជាបានការ។

+ក្រឡាបញ្ជី អានសារណាការពាររបស់មេធាវីលោក [redacted]ណាក់ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់អំណានសារណារបស់មេធាវីការពារសិទ្ធិជនត្រូវចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

Scanned with CamScanner

## សំអាងហេតុ

១.យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣២ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ របស់លោក[redacted]ណាក់ មេធាវីការពារសិទ្ធិជនត្រូវចោទ [redacted] គង់ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និង មាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.យល់ឃើញថា តាមសារណាការការពារជនត្រូវចោទ បានលើកឡើងថា សំណុំរឿងព្រហ្មទណ្ឌផ្នែកអង្គសេចក្តី ត្រូវបានសាលាដំបូងខេត្តស្វាយរៀង បានលើកយកមកជំនុំជម្រះ ហើយបានសម្រេចសេចក្តីតាមសាលក្រមព្រហ្មទណ្ឌលេខ ៩០ ច ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩ សម្រេចផ្តន្ទាទោសជនជាប់ចោទ[redacted]គង់ ដាក់ពន្ធនាគារកំណត់រយៈពេល ២ឆ្នាំ តែទោសនេះត្រូវព្យួរ និង សម្រេចបញ្ឈប់ការចាប់ខ្លួន សយ គង់ ហើយសាលក្រមនេះមិនមានបណ្តឹងឧទ្ធរណ៍ពីតំណាងអយ្យការទេ នោះ តុលាការកំពូលពិចារណាឃើញថា ការសម្រេចឃុំខ្លួនជនត្រូវចោទ[redacted]គង់ ពុំមានភាពចាំបាច់ទៀតហើយ។

៣.យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៧៣ ក្រIII "ស.អ" ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០១៨ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ សម្រេចសេចក្តីមកនេះ មិនត្រឹមត្រូវតាមច្បាប់ទេ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១.ទទួល បណ្តឹងសាទុក្ខលេខ ៣២ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ របស់លោក[redacted]ណាក់ មេធាវីការពារសិទ្ធិជនត្រូវចោទ [redacted]គង់ ។

២.បដិសេធ សាលដីកាព្រហ្មទណ្ឌលេខ ៧៣ ក្រIII "ស.អ" ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ ទាំងមូល ។

៣.តំកល់ ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នលេខ ៥៥០ ស.រ មយខ/១៨ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តស្វាយរៀង ។

៤.បង្គាប់ ឲ្យបញ្ឈប់ការចាប់-ឃុំខ្លួនជនត្រូវចោទ [redacted]គង់ ពីបទបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឲ្យមានរបួស និង ស្លាប់អ្នកដទៃដោយអចេតនា បើជននេះមិនត្រូវបានបង្គាប់ឲ្យ ចាប់ឬ ឃុំខ្លួនពីបទល្មើសផ្សេងទៀតទេ ។

Scanned with CamScanner

សាលដីកានេះ បានជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៥ ខែមករា ឆ្នាំ២០២០ និង ប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០។

Scanned with CamScanner